**ព្រះរាជក្រម**

នស/រកម/១២២០/០៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល
លេខ ១០៤
ថ្ងៃទី ១១/០១ ឆ្នាំ ២០២១ ម៉ោង ១៤:០០
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សម្រាប់ការគ្រប់គ្រង
# ឆ្នាំ២០១៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**គ១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................២៥ ៣៦០ ០២៨,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៣១ ០៥២ ១២២,៤ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុចំនួន.......................................៥ ៦៩២ ០៩៤,៤ លានរៀល។

**មាត្រា៣ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................២៨ ១៦១ ២៣០,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ២៧ ៣១៦ ៨៥៤,៩ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន....................................... ៨៤៤ ៣៧៥,១ លានរៀល។

**មាត្រា៤ .-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង "**ខ១**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "**គ១**" និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទនៅក្នុងតារាង "**គ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្ត មិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩៖ ចំពោះចំណូលថវិកាត្រូវបានបង្ហាញនៅក្នុង ចំណុច II នៃតារាង "**ខ១**" និងចំពោះចំណាយថវិកាត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**គ៣**" ដូចមានភ្ជាប់ជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា៥ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២០ ០៣៦ ២៦០,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................២៦ ០២៥ ០៣៣,២ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុចំនួន........................................៥ ៩៨៨ ៧៧៣,២ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.........................................១៩ ៥៩៣ ១១១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២៥ ៣៩៥ ០២១,៩ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន........................... ៥ ៨០១ ៩១០,៩ លានរៀល។

២. ចំណូលមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................... ៤៤៣ ១៤៩,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ៦៣០ ០១១,៣ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................១៨៦ ៨៦២,៣លានរៀល។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.........................................១៩៣ ១៤៩,០ លានរៀល
- អនុវត្តជាក់ស្តែង...................................... ១៨១ ៤២៦,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន........................... ១១ ៧២២,៣ លានរៀល។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ.......................................២៥០ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៤៤៨ ៥៨៤,៦ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន......................... ១៩៨ ៥៨៤,៦ លានរៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៦ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅៈ

- ច្បាប់ហិរញ្ញវត្ថុ.......................................២២ ៨៣៧ ៤៦២,០ លានរៀល
- អនុវត្តជាក់ស្តែង.............................. ២២ ២៨៩ ៧៦៥,៦ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន.......................................៥៤៧ ៦៩៦,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅៈ

១. ចំណាយចរន្ត
- ច្បាប់ហិរញ្ញវត្ថុ.......................................១៧ ៩៩៣ ៤៨២,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ១៧ ៨៨៩ ៤៩២,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..............................១០៣ ៩៨៩,១ លានរៀល។

២. ចំណាយមូលធន
- ច្បាប់ហិរញ្ញវត្ថុ....................................... ៤ ៨៤៣ ៩៨០,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៤ ៤០០ ២៧២,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..............................៤៤៣ ៧០៧,២ លានរៀល។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
- ច្បាប់ហិរញ្ញវត្ថុ.......................................៣ ៩៣៨ ០៣២,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៣ ៥១៥ ៧៨៣,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..............................៤២២ ២៣៨,៦ លានរៀល។

ខ. ចំណាយមូលធន សម្រាប់ការទូទាត់ការខ្ចី
- ច្បាប់ហិរញ្ញវត្ថុ....................................... ៩០៥ ៩៤៨,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៨៨៤ ៤៧៩,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..............................២១ ៤៦៨,៥ លានរៀល។

**មាត្រា៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាជាក់ស្តែងឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅៈ

- ចំណូលថវិកាអនុវត្តជាក់ស្តែង.............................. ២៦ ០២៥ ០៣៣,២ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.............................. ២២ ២៨៩ ៧៦៥,៦ លានរៀល
- អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំមានចំនួន...... (+) ៣ ៧៣៥ ២៦៧,៥ លានរៀល។

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៅក្នុងមាត្រា៧៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ មានចំនួនទឹកប្រាក់(+)៣ ៧៣៥ ២៦៧,៥ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលរបស់រតនាគារជាតិ។

## ផ្នែកទី៣
## បទប្បញ្ញត្តិស្ដីពី
## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

**មាត្រា៨ ._**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៦១ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងយោងមាត្រា១១នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងយោងតាមតម្រូវការចាំបាច់ជាក់ស្ដែងរបស់រាជរដ្ឋាភិបាល ត្រូវបានអនុម័តយល់ព្រមលើកិច្ចប្រតិបត្តិការចំណាយឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដូចខាងក្រោម៖

១-ផ្ដល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់ទូទាត់ចំណាយបំពេញតម្រូវការឥណទានរបស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីប្រមូលទិញស្រូវពីប្រជាកសិករនៅរដូវប្រមូលផលចុងឆ្នាំ២០១៨ និងដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវបង្កើនដើមទុនក្នុងការស្នើសុំអាជ្ញាបណ្ណជាធនាគារពាណិជ្ជ៖

- ឥណទានថវិកាបន្ថែម.................................... ២០៤ ២០០,០ លានរៀល
- អនុវត្តជាក់ស្ដែង............................................. ២០២ ២០០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.......................... ២ ០០០,០ លានរៀល។

២-ប្រតិបត្តិការថវិកាបន្ថែមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖

ក. ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីបែងចែកទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត៖

- ឥណទានថវិកាបន្ថែម.....................................៣៤២ ៤៥០,០ លានរៀល
- អនុវត្តជាក់ស្ដែង..............................................៣៣២ ៣១០,០ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែមចំនួន.......................១០ ១៤០,០ លានរៀល។

ខ. ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលក្រុង ស្រុក ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន៖

- ឥណទានថវិកាបន្ថែម .................................... ១១ ៣៤៥,១ លានរៀល
- អនុវត្តជាក់ស្ដែង............................................. ១១ ៣៤៥,១ លានរៀល។

គ. ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន៖

- ឥណទានថវិកាបន្ថែម .................................. ១៣៧ ២០៣,១ លានរៀល
- អនុវត្តជាក់ស្ដែង............................................ ១៣៧ ២០៣,១ លានរៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣-យល់ព្រមឱ្យរាជរដ្ឋាភិបាលអនុញ្ញាតឱ្យអគ្គិសនីកម្ពុជាខ្ចីនិងទូទាត់នូវទឹកប្រាក់ចំនួន ១ ២៣០ ០០០ លានរៀល (មួយទ្រីលានពីររយសាមសិបប៊ីលានរៀលគត់) សម្រាប់អនុវត្តគម្រោងសាងសង់រោងចក្រអគ្គិសនីដើរដោយប្រេងខ្មៅ និងឧស្ម័នអានុភាព៤០០ មេហ្គាវ៉ាត់ និងទឹកប្រាក់ចំនួន៨១ ០០០លានរៀល (ប៉ែតសិបមួយប៊ីលានរៀលគត់) សម្រាប់អនុវត្តគម្រោងពង្រីកប្រព័ន្ធបញ្ជូន និងចែកចាយអគ្គិសនី ២០១៩-២០២១។

## ផ្នែកទី៤

## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តមិនឆ្លងកាត់រតនាគារជាតិ

**មាត្រា៩ .-**

ការអនុវត្តចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តមិនឆ្លងកាត់រតនាគារជាតិ ដែលបានគ្រោងទុកចំណូលសរុបស្មើនឹងចំណាយសរុបសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................៥ ៣២៣ ៧៦៨,០ លានរៀល
- អនុវត្តជាក់ស្តែង....................................... ៥ ០២៧ ០៨៩,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............................ ២៩៦ ៦៧៨,៨ លានរៀល។

## ផ្នែកទី៥

## តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

**មាត្រា១០ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលក្នុងប្រទេសអនុវត្តជាក់ស្តែង.................. ២៥ ៥៧៦ ៤៤៨,៦ លានរៀល
  ក្នុងនោះចំណូលចរន្តអនុវត្តជាក់ស្តែង.................២៥ ៣៩៥ ០២១,៩ លានរៀល
- ចំណាយថវិកា(មិនគិតការទូទាត់ការខ្ចី)
  អនុវត្តជាក់ស្តែង........................................២៦ ៤៣២ ៣៧៥,៤ លានរៀល
  ក្នុងនោះចំណាយចរន្តអនុវត្តជាក់ស្តែង.............. ១៧ ៨៨៩ ៤៩២,៩ លានរៀល
- អតិរេកនៃថវិកាចរន្ត ................................ (+)៧ ៥០៥ ៥២៩,០ លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិមានចំនួន........... (-)៨៥៥ ៩២៦,៨ លានរៀល
- ហិរញ្ញប្បទាននៃឱនភាពមានចំនួន..................... (+)៨៥៥ ៩២៦,៨ លានរៀល។

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "**ក២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

# ជំពូកទី២
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តជំពូកទី៥ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៧។

លទ្ធផលដែលបានសម្រេចពីការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩៖ កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានបង្ហាញលម្អិត នៅក្នុងតារាង "**ក៣**" កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានបង្ហាញលម្អិតនៅក្នុង តារាង "**ក៤**" និងកិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្ហាញលម្អិតនៅក្នុង តារាង "**ក៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

**មាត្រា១២ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៨៣០ ៣១៤,០ លានរៀល
- អនុវត្តជាក់ស្ដែង..........................................២ ៥៨៩ ៥៨១,០ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត អនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុចំនួន........................................ ៧៥៩ ២៦៧,០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៣៩៣ ១៣៨,០ លានរៀល
- អនុវត្តជាក់ស្ដែង.......................................... ២ ១៦២ ៥៤៥,០ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន...............................៧៦៩ ៤០៧,០ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ
- ច្បាប់ហិរញ្ញវត្ថុ.......................................... ៤៣៧ ១៧៦,០ លានរៀល
- អនុវត្តជាក់ស្ដែង..........................................៤២៧ ០៣៦,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................. ១០ ១៤០,០ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិត [illegible] នៅក្នុងតារាង "**ខ២**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា១៣ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................................ ១ ៨២០ ១៧២,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................................ ២ ៣៥៤ ០៥២,៦ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានខ្ពស់ជាង ច្បាប់ហិរញ្ញវត្ថុចំនួន............................................. ៥៣៣ ៨៨០,១ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................................ ១ ៣៧០ ៦០៩,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................................ ១ ៨៧៤ ៨២៥,២ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................... ៥០៤ ២១៥,៧ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ........................................................ ៤៤៩ ៥៦៣,០ លានរៀល
- អនុវត្តជាក់ស្តែង........................................................ ៤៧៩ ២២៧,៣ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................... ២៩ ៦៦៤,៣ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ១ នៃតារាង "**គ៤**" និងត្រូវបានលម្អិតតាមរដ្ឋបាលរាជធានី ខេត្ត និងតាមជំពូកនៅក្នុងតារាង "**គ៥**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៤ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.................................. ២ ៥៨៩ ៥៨១,០ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.................................. ២ ៣៥៤ ០៥២,៦ លានរៀល
- អតិរេកនៃថវិកាមានចំនួន.....................................(+)២៣៥ ៥២៨,៤ លានរៀល។

អនុលោមតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានទឹកប្រាក់ចំនួន(+)២៣៥ ៥២៨,៤លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំថវិកា

## ផ្នែកទី៣
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា១៥ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.................................................២៣៦ ៥១៨,៣ លានរៀល
- អនុវត្តជាក់ស្ដែង............................................ ២៤០ ០៩១,៥ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុចំនួន............................................ ៣ ៥៧៣,២ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.................................................២៤ ០១០,២ លានរៀល
- អនុវត្តជាក់ស្ដែង............................................ ២៧ ៩០០,៩ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................... ៣ ៨៩០,៧ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ................................................ ២០១ ១៦៣,០ លានរៀល
- អនុវត្តជាក់ស្ដែង............................................ ២០០ ៨៤៥,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................... ៣១៧,៥ លានរៀល។

៣. អតិរេកឆ្នាំ២០១៨ មានចំនួន.................................. ១១ ៣៤៥,១ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង "**២៣**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៦ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.................................................២៣៦ ៥១៨,៣ លានរៀល
- អនុវត្តជាក់ស្ដែង................................................២៣៣ ៨៦៦,២ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន............................................ ២ ៦៥២,១ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ................................................ ២៣៥ ៨៧៦,៨ លានរៀល
- អនុវត្តជាក់ស្ដែង............................................២៣៣ ២៣០,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.................................. ២ ៦៤៦,១ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ....................................................៦៤១,៥ លានរៀល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- អនុវត្តជាក់ស្តែង.................................................... ៦៣៥,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................... ៦,០ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ២ នៃតារាង "**គ៤**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.............................. ២៤០ ០៩១,៥ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង............................ ២៣៣ ៨៦៦,២ លានរៀល
- អតិរេកនៃថវិកាមានចំនួន.................................(+)៦ ២២៥,៣ លានរៀល។

អនុលោមតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលមានទឹកប្រាក់ចំនួន+៦ ២២៥,៣លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៤
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

**មាត្រា១៨ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.............................................. ៦៦១ ០០៣,១ លានរៀល
- អនុវត្តជាក់ស្តែង............................................ ៦៨៤ ៧៧១,៩ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុចំនួន........................................ ២៣ ៧៦៨,៨ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលមិនមែនសារពើពន្ធ

- ច្បាប់ហិរញ្ញវត្ថុ.................................................... ០,០ លានរៀល
- អនុវត្តជាក់ស្តែង............................................ ២៣ ៧៦៨,៨ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................. ២៣ ៧៦៨,៨ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ.............................................. ៥២៣ ៨០០,០ លានរៀល

- អនុវត្តជាក់ស្តែង.......................................................៥២៣ ៨០០,០ លានរៀល

៣. អតិរេកឆ្នាំ២០១៨ មានចំនួន..................................១៣៧ ២០៣,១ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមមាតិកានៅក្នុងតារាង "ខ៤" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៩ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................................៦៦១ ០០៣,១ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៥៤៤ ៧០២,៧ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន.................................................១១៦ ៣០០,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយសង្កាត់ចំណុះរាជធានី

- ច្បាប់ហិរញ្ញវត្ថុ.......................................................៤៧ ៧០៨,៧ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៤២ ២៤៦,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................៥ ៤៦២,៣ លានរៀល។

២. ចំណាយសង្កាត់ចំណុះក្រុង

- ច្បាប់ហិរញ្ញវត្ថុ.......................................................៥៤ ០៣៥,៧ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៤១ ៧៣៦,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................១២ ២៩៩,១ លានរៀល។

៣. ចំណាយឃុំ

- ច្បាប់ហិរញ្ញវត្ថុ.......................................................៥៥៩ ២៥៨,៧ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៤៦០ ៧១៩,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................................៩៨ ៥៣៨,៩ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ៣ នៃតារាង "គ៤" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២០ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.......................................៦៨៤ ៧៧១,៩ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.......................................៥៤៤ ៧០២,៧ លានរៀល
- អតិរេកនៃថវិកាមានចំនួន.......................................(+)១៤០ ០៦៩,២ លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ អតិរេកថវិការដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០១៩ ដែលមានទឹកប្រាក់ចំនួន+១៥០ ០៦៩,២លានរៀល ត្រូវយោងបន្តទៅឆ្នាំ២០២០។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ១១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០២០

នស/រកម.១២១៩.០១៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក១"

## កិច្ចប្រតិបត្តិការទូទៅថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = ( I.១ + II.១ ) | 25,360,028.0 | 31,052,122.4 | 122.4% | +5,692,094.4 |
| សរុបចំណាយ = ( I.២ + II.២ ) | 28,161,230.0* | 27,316,854.9 | 97.0% | -844,375.1 |
| អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +3,735,267.5 | | |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | 20,036,260.0 | 26,025,033.2 | 129.9% | +5,988,773.2 |
| · ចំណូលចរន្ត | 19,593,111.0 | 25,395,021.9 | 129.6% | +5,801,910.9 |
| · ចំណូលមូលធន | 443,149.0 | 630,011.3 | 142.2% | +186,862.3 |
| + ចំណូលមូលធនក្នុងប្រទេស | 193,149.0 | 181,426.7 | 93.9% | -11,722.3 |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | 250,000.0 | 448,584.6 | 179.4% | +198,584.6 |
| I.២.ចំណាយថវិកា | 22,837,462.0 | 22,289,765.6 | 97.6% | -547,696.4 |
| · ចំណាយចរន្ត | 17,993,482.0* | 17,889,492.9 | 99.4% | -103,989.1 |
| · ចំណាយមូលធន | 4,843,980.0 | 4,400,272.8 | 90.8% | -443,707.2 |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 3,938,032.0 | 3,515,793.3 | 89.3% | -422,238.7 |
| + ការទូទាត់ការខ្ចី | 905,948.0 | 884,479.5 | 97.6% | -21,468.5 |
| II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 5,323,768.0 | 5,027,089.2 | 94.4% | -296,678.8 |
| II.២.ចំណាយមូលធនសម្រាប់គម្រោង ដោយហិរញ្ញប្បទានក្រៅប្រទេស | 5,323,768.0 | 5,027,089.2 | 94.4% | -296,678.8 |

(*)តួលេខនេះបូកបញ្ចូលនូវៈ (១)-ឥណទានថវិកាចំនួន១ ៤៣៤ ២០០,០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃ កិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និង(២)-ឥណទានថវិកាចំនួន៩៦២ ០០២,០លានរៀល ត្រូវបានបែងចែកឡើងវិញ ដោយយោងប្រកាសបន្ថែមឥណទានថវិកា អនុលោមតាមមាត្រា៤២(ថ្មី) នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក២"

## តុល្យភាពនៃថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I- ចំណូលក្នុងប្រទេសសរុប | 25,576,448.6 | |
| I.១. ចំណូលចរន្ត | 25,395,021.9 | |
| I.២. ចំណូលមូលធនក្នុងប្រទេស | 181,426.7 | |
| II- ចំណាយថវិកាសរុប | 26,432,375.4 | |
| II.១. ចំណាយចរន្ត | 17,889,492.9 | |
| II.២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី ចំនួន៨៨៤ ៤៧៩,៥លានរៀល) | 8,542,882.6 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 3,515,793.3 | |
| - ដោយថវិកាថ្នាក់ជាតិ | 3,410,731.4 | |
| • គម្រោងវិនិយោគផ្ទាល់ | 2,892,055.3 | |
| • បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស | 518,676.1 | |
| - ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | 105,061.9 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5,027,089.2 | |
| ក. អតិរេកនៃថវិកាចរន្ត (I.១-II.១) | (+)7,505,529.0 | |
| ខ. ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | (-)855,926.8 | |
| III- ហិរញ្ញប្បទាននៃឱនភាព | | (+)855,926.8 |
| ១. ហិរញ្ញប្បទានពីក្រៅប្រទេស | | (+)4,591,194.3 |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | | (+)448,584.6 |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)5,027,089.2 |
| • ការទូទាត់ការខ្ចី | | (-)884,479.5 |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (-)3,735,267.5 |
| • បញ្ញើរាជរដ្ឋាភិបាល | | (-)3,735,267.5 |

* ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក៣"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលរាជធានី ខេត្ត | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូលថវិកា | 1,830,314.0* | 2,589,581.0 | 141.5% | +759,267.0 |
| សរុបចំណាយថវិកា | 1,820,172.5** | 2,354,052.6 | 129.3% | +533,880.1 |
| អតិរេកថវិការវាងចំណូលនិងចំណាយ | | 235,528.4 | | |
| កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត | | | | |
| I. ចំណូលថវិកា | 1,830,314.0* | 2,589,581.0 | 141.5% | +759,267.0 |
| - ចំណូលចរន្ត | 1,393,138.0 | 2,162,545.0 | 155.2% | +769,407.0 |
| • ចំណូលសារពើពន្ធ | 1,351,616.7 | 2,113,743.0 | 156.4% | +762,126.3 |
| • ចំណូលមិនមែនសារពើពន្ធ | 41,521.3 | 48,801.9 | 117.5% | +7,280.6 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 437,176.0* | 427,036.0 | 97.7% | -10,140.0 |
| II. ចំណាយថវិកា | 1,820,172.5** | 2,354,052.6 | 129.3% | +533,880.1 |
| - ចំណាយចរន្ត | 1,370,609.5 | 1,874,825.2 | 136.8% | +504,215.7 |
| - ចំណាយមូលធន | 449,563.0 | 479,227.3 | 106.6% | +29,664.3 |

(*) តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន៣៤២ ៤៥០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ (២)-ឥណទានចំនួន៥ ៩៩០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប និង(៣)-ឥណទានចំនួន ៤ ៩២៨លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកា សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩ ជូនរដ្ឋបាលរាជធានី ខេត្តចំនួន១៨ ដើម្បីអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋបាលរាជធានី ខេត្ត

(**)តួលេខនេះបូកបញ្ចូលនូវឥណទានសរុបចំនួន៣៤៣ ២២៨លានរៀល រួមមានចំណាយចរន្តចំនួន២៥៤ ៩៦៤លានរៀល និង ចំណាយមូលធនចំនួន៨៨ ២៦៤លានរៀល ដែលក្នុងនោះ៖ (១)-ឥណទានចំនួន៣៣២ ៣១០លានរៀល ដោយយោងប្រកាសបន្ថែមឥណទាន ដើម្បីបែងចែកទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត (២)-ឥណទានចំនួន៥ ៩៩០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកា ជូនសាលាខេត្តសៀមរាប និង(៣)-ឥណទានចំនួន៤ ៩២៨លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋរបស់រដ្ឋបាលរាជធានី ខេត្ត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក៤"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលក្រុង ស្រុក | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល | 236,518.3 | 240,091.5 | 101.5% | +3,573.2 |
| សរុបចំណាយ | 236,518.3 | 233,866.2 | 98.9% | -2,652.1 |
| អតិរេកថវិការវាងចំណូល និងចំណាយ | | +6,225.3 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលក្រុង ស្រុក | | | | |
| I. ចំណូលថវិកា | 236,518.3 | 240,091.5 | 101.5% | +3,573.2 |
| - ចំណូលចរន្ត | 24,010.2 | 27,900.9 | 116.2% | +3,890.7 |
| • ចំណូលមិនមែនសារពើពន្ធ | 24,010.2* | 27,900.9 | 116.2% | +3,890.7 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 201,163.0** | 200,845.5 | 99.8% | -317.5 |
| - អតិរេកឆ្នាំ២០១៨ | 11,345.1*** | 11,345.1 | 100.0% | 0.0 |
| II. ចំណាយថវិកា | 236,518.3 | 233,866.2 | 98.9% | -2,652.1 |
| - ចំណាយចរន្ត | 235,876.8**** | 233,230.7 | 98.9% | -2,646.1 |
| - ចំណាយមូលធន | 641.5***** | 635.5 | 99.1% | -6.0 |

(*) តួលេខនេះបូកបញ្ចូលឥណទានចំនួនចំនួន៩ ១៨០,២លានរៀល ពីប្រភពការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ៣% និងតួលេខថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន។

(**) តួលេខនេះបូកបញ្ចូលនូវតួលេខនេះបូកបន្ថែមថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣១ស្រុក ចំនួន៩ ១០៣,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍។

(***) តួលេខនេះបូកបញ្ចូលឥណទានថវិកាចំនួន១១ ៣៤៥,១លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

(****)តួលេខនេះ បាន៖ (១)-បូកបញ្ចូលនូវ៖ (ក)-ឥណទានចំនួនចំនួន១១ ២៣៤,៦លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០និង(ខ)-ឥណទានចំនួន៩ ១៨០,២លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ៣% សម្រាប់ចំណាយអភិវឌ្ឍន៍ (គ)-ប្រកាសបន្ថែមឥណទានថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន (ឃ)-ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣១ស្រុក ចំនួន៨ ៦៧០,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ និង(២)-ផ្ទេរឥណទានចំនួន៩៨,០លានរៀល ចេញពីអនុគណនី៦១០៥៤ ទៅចំណាយមូលធនក្នុងអនុគណនី២១០៤៦ ជូនរដ្ឋបាលស្រុកគិរីវង្ស។

(*****)តួលេខនេះបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន៥៤៣,៥លានរៀល ដោយបន្ថែមឥណទានជូនរដ្ឋបាលស្រុកសំរោងទង [illegible] ក្នុងនោះមាន មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ(SNIF) ចំនួន៤៣៣,០លានរៀល និងការផ្ទេរមុខងារ [illegible]អភិវឌ្ឍន៍[illegible]បទចំនួន១១០,៥លានរៀល សម្រាប់ធ្វើផ្លូវលំជនបទដោយការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ [illegible]សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និង (២)-ឥណទាន[illegible]ចំនួន៩៨,០លានរៀល ដោយការធ្វើនិយ័តភាពឥណទានផ្ទៃក្នុងពីចំណាយចរន្តជូនរដ្ឋបាលស្រុកគិរីវង្ស [illegible] សម្រាប់ការងារសាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈ។

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ក៥"

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល | 661,003.1 | 684,771.9 | 103.6% | +23,768.8 |
| សរុបចំណាយ | 661,003.1 | 544,702.7 | 82.4% | -116,300.4 |
| អតិរេកថវិការវាងចំណូលនិងចំណាយ | | +140,069.2 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលឃុំ សង្កាត់ | | | | |
| I. ចំណូលថវិកា | 661,003.1 | 684,771.9 | 103.6% | +23,768.8 |
| - ចំណូលមិនមែនសារពើពន្ធ | 0.0 | 23,768.8 | | +23,768.8 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 0.0 | 10,684.0 | | +10,684.0 |
| · ចំណូលសង្កាត់ចំណុះក្រុង | 0.0 | 1,216.3 | | +1,216.3 |
| · ចំណូលឃុំ | 0.0 | 11,868.5 | | +11,868.5 |
| - ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប | 523,800.0 | 523,800.0 | 100.0% | 0.0 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 36,845.4 | 36,845.4 | 100.0% | 0.0 |
| · ចំណូលសង្កាត់ចំណុះក្រុង | 40,634.4 | 40,634.4 | 100.0% | 0.0 |
| · ចំណូលឃុំ | 446,320.2 | 446,320.2 | 100.0% | 0.0 |
| - អតិរេកឆ្នាំ២០១៨ | 137,203.1* | 137,203.1 | 100.0% | 0.0 |
| II. ចំណាយថវិកា | 661,003.1 | 544,702.7 | 82.4% | -116,300.4 |
| - ចំណាយសរុប | 661,003.1* | 544,702.7 | 82.4% | -116,300.4 |
| · ចំណាយសង្កាត់ចំណុះរាជធានី | 47,708.7 | 42,246.3 | 88.6% | -5,462.3 |
| · ចំណាយសង្កាត់ចំណុះក្រុង | 54,035.7 | 41,736.6 | 77.2% | -12,299.1 |
| · ចំណាយឃុំ | 559,258.7 | 460,719.8 | 82.4% | -98,539.0 |

( * ) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន១៣៧ ២០៣,១លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

# ការគ្រប់គ្រងឆ្នាំ២០១៩
## តារាង "ខ១"
## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| **សរុបរួមចំណូលថវិកា (I+II)** | | | | 25.360.028.000.000 | 31.052.122.475.894 | 122,4% | +5.692.094.475.894 |
| **I. សរុបចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិ (ក+ខ)** | | | | 20.036.260.000.000 | 26.025.033.246.433 | 129,9% | +5.988.773.246.433 |
| **ក្នុងនោះ ចំណូលក្នុងប្រទេស** | | | | 19.786.260.000.000 | 25.576.448.682.021 | 129,3% | +5.790.188.682.021 |
| **ក. សរុបចំណូលចរន្ត (ក្រ១)** | | | | 19.593.111.000.000 | 25.395.021.936.034 | 129,6% | +5.801.910.936.034 |
| **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | | | | 19.593.111.000.000 | 25.395.021.936.034 | 129,6% | +5.801.910.936.034 |
| | **ប្រភេទទី១: ចំណូលសារពើពន្ធ** | | | 16.879.000.000.000 | 22.052.933.858.987 | 130,7% | +5.173.933.858.987 |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 14.468.000.000.000 | 19.140.031.485.324 | 132,3% | +4.672.031.485.324 |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 4.330.000.000.000 | 5.045.260.802.580 | 116,5% | +715.260.802.580 |
| | | 70011 | ពន្ធលើប្រាក់ចំណូល(រូបវន្តបុគ្គល) | 210.000.000.000 | 142.285.152.275 | 67,8% | -67.714.847.725 |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 3.250.000.000.000 | 4.055.158.012.994 | 124,8% | +805.158.012.994 |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 870.000.000.000 | 847.817.637.311 | 97,5% | -22.182.362.689 |
| | 7002 | | ពន្ធប្រយោល | 5.901.500.000.000 | 7.410.018.869.815 | 125,6% | +1.508.518.869.815 |
| | | 70021 | អាករលើផលរបរ | 0 | 13.693.192 | | +13.693.192 |
| | | 70022 | អាករលើតម្លៃបន្ថែម | 2.370.500.000.000 | 2.772.684.190.782 | 117,0% | +402.184.190.782 |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 851.000.000.000 | 832.057.829.761 | 97,8% | -18.942.170.239 |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.362.000.000.000 | 3.487.263.156.080 | 147,6% | +1.125.263.156.080 |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល (ជាបន្ទុករបស់រដ្ឋ) | 318.000.000.000 | 318.000.000.000 | 100,0% | 0 |
| | 7003 | | អាករពិសេស | 4.137.000.000.000 | 6.477.641.068.046 | 156,6% | +2.340.641.068.046 |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 900.000.000.000 | 1.027.475.796.968 | 114,2% | +127.475.796.968 |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 498.000.000.000 | 642.607.351.176 | 129,0% | +144.607.351.176 |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.654.000.000.000 | 4.704.576.009.857 | 177,3% | +2.050.576.009.857 |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 85.000.000.000 | 102.981.910.045 | 121,2% | +17.981.910.045 |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 99.500.000.000 | 207.110.744.883 | 208,2% | +107.610.744.883 |
| | | 70081 | ពន្ធតែមប្រ៍ | 9.500.000.000 | 15.969.583.337 | 168,1% | +6.469.583.337 |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 90.000.000.000 | 191.141.161.546 | 212,4% | +101.141.161.546 |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | **2.411.000.000.000** | **2.912.902.373.663** | **120,8%** | **+501.902.373.663** |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.361.000.000.000 | 2.863.399.056.977 | 121,3% | +502.399.056.977 |
| | | 71001 | ពន្ធគយពីការនាំចូល | 1.563.000.000.000 | 2.081.312.346.909 | 133,2% | +518.312.346.909 |
| | | 71002 | កម្រៃពីការងារគយ | 98.000.000.000 | 63.059.658.509 | 64,3% | -34.940.341.491 |
| | | 71003 | ពន្ធគយលើផលិតផលតេលសិលា | 340.000.000.000 | 309.762.341.163 | 91,1% | -30.237.658.837 |
| | | 71004 | អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 342.000.000.000 | 383.134.362.196 | 112,0% | +41.134.362.196 |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | 500.000.000 | 194.362.286 | 38,9% | -305.637.714 |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 12.000.000.000 | 14.935.985.914 | 124,5% | +2.935.985.914 |
| | | 71007 | ពន្ធនាំចូល (ជាបន្ទុករបស់រដ្ឋ) | 5.500.000.000 | 11.000.000.000 | 200,0% | +5.500.000.000 |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 50.000.000.000 | 49.503.316.686 | 99,0% | -496.683.314 |
| | | 71011 | អាករលើការនាំចេញឈើ | 10.000.000.000 | 8.402.679.470 | 84,0% | -1.597.320.530 |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 33.000.000.000 | 32.852.913.567 | 99,6% | -147.086.433 |

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ខ១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 6.500.000.000 | 7.523.243.441 | 115,7% | +1.023.243.441 |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500.000.000 | 724.480.208 | 144,9% | +224.480.208 |
| | **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | **2.714.111.000.000** | **3.342.088.077.047** | 123,1% | **+627.977.077.047** |
| **72** | | | ផលខុននៃទ្រព្យសម្បត្តិរដ្ឋ | **127.416.500.000** | **273.822.790.075** | **214,9%** | **+146.406.290.075** |
| | 7200 | | ផលសម្បទាន | 106.166.500.000 | 102.738.101.170 | 96,8% | -3.428.398.830 |
| | | 72001 | ផលពីនេសាទ | 2.650.000.000 | 1.618.277.000 | 61,1% | -1.031.723.000 |
| | | 72002 | ផលពីព្រៃឈើ | 17.412.600.000 | 17.345.783.673 | 99,6% | -66.816.327 |
| | | 72003 | សម្បទានប្រេងកាត | 6.166.000.000 | 6.443.650.300 | 104,5% | +277.650.300 |
| | | 72004 | សម្បទានរ៉ែ | 71.842.900.000 | 64.036.255.025 | 89,1% | -7.806.644.975 |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 7.000.000.000 | 12.053.642.834 | 172,2% | +5.053.642.834 |
| | | 72008 | ផលសម្បទានផ្សេងៗ | 1.095.000.000 | 1.240.492.338 | 113,3% | +145.492.338 |
| | 7201 | | ផលខុនពីសហគ្រាសសាធារណៈ | 21.250.000.000 | 171.084.688.905 | 805,1% | +149.834.688.905 |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 21.250.000.000 | 171.084.688.905 | 805,1% | +149.834.688.905 |
| **73** | | | ផលខុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | **2.295.830.900.000** | **2.667.625.692.254** | **116,2%** | **+371.794.792.254** |
| | 7300 | | ផលខុនតាមវិស័យ | 955.976.300.000 | 807.827.824.056 | 84,5% | -148.148.475.944 |
| | | 73001 | ផលខុនអាកាសចរណ៍ស៊ីវិល | 247.016.000.000 | 216.531.151.999 | 87,7% | -30.484.848.001 |
| | | 73003 | ផលខុននៃសកម្មភាពទេសចរណ៍ | 470.464.500.000 | 375.790.938.905 | 79,9% | -94.673.561.095 |
| | | 73004 | ផលខុននៃសកម្មភាពវប្បធម៌ | 47.132.500.000 | 34.988.410.612 | 74,2% | -12.144.089.388 |
| | | 73005 | ផលខុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 187.335.000.000 | 172.755.957.637 | 92,2% | -14.579.042.363 |
| | | 73006 | ផលខុនពីវិទ្យុ និងទូរទស្សន៍ | 1.164.200.000 | 884.916.000 | 76,0% | -279.284.000 |
| | | 73007 | ផលខុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 36.800.000 | 65.887.700 | 179,0% | +29.087.700 |
| | | 73008 | ផលខុនផ្សេងៗទៀត | 2.827.300.000 | 6.810.561.203 | 240,9% | +3.983.261.203 |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 103.667.900.000 | 148.651.118.385 | 143,4% | +44.983.218.385 |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 124.000.000 | 26.040.000 | 21,0% | -97.960.000 |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 103.171.900.000 | 146.274.042.949 | 141,8% | +43.102.142.949 |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 5.000.000 | 0 | 0,0% | -5.000.000 |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 262.000.000 | 261.394.390 | 99,8% | -605.610 |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬខូច | 23.000.000 | 198.104.700 | 861,3% | +175.104.700 |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬខូច | 3.000.000 | 797.000 | 26,6% | -2.203.000 |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬខូច | 2.000.000 | 2.340.000 | 117,0% | +340.000 |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 77.000.000 | 1.888.399.346 | 2.452,5% | +1.811.399.346 |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (១) | 32.889.500.000 | 91.264.682.779 | 277,5% | +58.375.182.779 |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | 0 | 3.000.000 | | +3.000.000 |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 24.635.300.000 | 41.673.292.370 | 169,2% | +17.037.992.370 |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 2.075.500.000 | 1.851.635.000 | 89,2% | -223.865.000 |
| | | 73026 | ចំណូលពីប្រដាប់ក្តី | 4.248.400.000 | 5.420.342.508 | 127,6% | +1.171.942.508 |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាល ផ្សេងៗ | 1.930.300.000 | 42.316.412.901 | 2.192,2% | +40.386.112.901 |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០១៩

## តារាង "ខ១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០១៩ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | 7304 | | ការផ្តល់សេវាកម្ម | 75.095.000.000 | 171.058.895.985 | 227,8% | +95.963.895.985 |
| | | 73042 | កម្រៃនៃការថែទាំ | 10.870.400.000 | 16.521.031.133 | 152,0% | +5.650.631.133 |
| | | 73043 | សេវាសុរិយោដី | 43.125.000.000 | 93.687.857.022 | 217,2% | +50.562.857.022 |
| | | 73044 | សេវាសំណង់ | 10.284.000.000 | 32.393.747.113 | 315,0% | +22.109.747.113 |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.581.200.000 | 2.352.339.700 | 91,1% | -228.860.300 |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 2.000.000.000 | 5.521.736.700 | 276,1% | +3.521.736.700 |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 6.234.400.000 | 20.582.184.317 | 330,1% | +14.347.784.317 |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 322.156.400.000 | 467.377.145.627 | 145,1% | +145.220.745.627 |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 226.511.000.000 | 344.746.740.479 | 152,2% | +118.235.740.479 |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 2.509.700.000 | 3.519.932.512 | 140,3% | +1.010.232.512 |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 50.000.000 | 28.800.000 | 57,6% | -21.200.000 |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 40.085.700.000 | 67.602.397.621 | 168,6% | +27.516.697.621 |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ. | 53.000.000.000 | 51.479.275.015 | 97,1% | -1.520.724.985 |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 32.692.700.000 | 32.884.516.684 | 100,6% | +191.816.684 |
| | | 73071 | ការជួលដីទំនេរ | 16.628.400.000 | 18.784.844.208 | 113,0% | +2.156.444.208 |
| | | 73072 | ការជួលដីមានអគារ | 12.823.900.000 | 13.713.850.290 | 106,9% | +889.950.290 |
| | | 73073 | ការជួលអគារ ឬសំណង់ផ្សេងៗ | 3.000.000.000 | 144.935.250 | 4,8% | -2.855.064.750 |
| | | 73074 | ការជួលសម្ភារ បរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 240.400.000 | 240.886.936 | 100,2% | +486.936 |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (២) | 773.353.100.000 | 948.561.508.738 | 122,7% | +175.208.408.738 |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 181.924.000.000 | 173.305.482.748 | 95,3% | -8.618.517.252 |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 446.757.000.000 | 688.706.344.912 | 154,2% | +241.949.344.912 |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 4.300.000.000 | 5.901.095.400 | 137,2% | +1.601.095.400 |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 6.493.800.000 | 7.961.996.241 | 122,6% | +1.468.196.241 |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 6.075.400.000 | 10.047.207.142 | 165,4% | +3.971.807.142 |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 5.272.800.000 | 8.915.137.119 | 169,1% | +3.642.337.119 |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 122.530.100.000 | 53.724.245.176 | 43,8% | -68.805.854.824 |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **31.274.300.000** | **44.124.298.813** | **141,1%** | **+12.849.998.813** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 22.212.300.000 | 44.018.128.813 | 198,2% | +21.805.828.813 |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 10.000.000.000 | 4.014.036.900 | 40,1% | -5.985.963.100 |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 12.212.300.000 | 40.004.091.913 | 327,6% | +27.791.791.913 |
| | 7403 | | ចំណូលពីការរឹបអូស | 9.000.000.000 | 2.670.000 | 0,0% | -8.997.330.000 |
| | | 74031 | ចំណូលពីការរឹបអូសប្រាក់កក់ | 0 | 2.670.000 | | +2.670.000 |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 9.000.000.000 | 0 | 0,0% | -9.000.000.000 |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 62.000.000 | 103.500.000 | 166,9% | +41.500.000 |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 62.000.000 | 103.500.000 | 166,9% | +41.500.000 |
